CITY OF LONGBEACH PUBLIC NOTICE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៤ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចនឹងចែកខែលការពារមុខដោយឥតគិតថ្លៃបន្ថែមដល់របារភោជនីយដ្ឋាននិងហាងថែសម្ផស្សនិងថែខ្លួននៅឡុងប៊ិច

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងឡុងប៊ិចនឹងចែកខែលការពារមុខដោយឥតគិតថ្លៃដល់បារ ភោជនីយដ្ឋាន និងអាជីវកម្មថែសម្ផស្សនិងថែខ្លួននៅឡុងប៊ិចក្នុងកិច្ចខិតខំផ្តល់នូវឧបករណ៍សុវត្ថិភាព ដែលជាតម្រូវការចាំបាច់ដល់អាជីវកម្មដែលអាចនឹងមិនមានលទ្ធភាពបើកជាថ្មីភ្លាមៗបាននៅថ្ងៃខាង មុខនេះ។

បទបញ្ជាសុខភាពដែលមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ១៩ ខែមិថុនាតម្រូវឱ្យអតិថិជនបារនិងកន្លែងធ្វើ ស្រាទំពាំងបាយជូរពាក់របាំងមុខនៅពេលចូលទៅក្នុងទីតាំងឬដើរពីកន្លែងមួយទៅកន្លែងមួយនៅក្នុង ហាងនិងតម្រូវអោយអ្នកលាយស្រានិង/ឬអ្នករត់តុពាក់របាំងមុខនិងខែលការពារមុខសម្រាប់ការពារនៅ ពេលបម្រើដល់អតិថិជនដែលមិនបានពាក់របាំងមុខ។ អ្នករត់តុនៅក្នុងភោជនីយដ្ឋានដែលបើកសម្រាប់ បរិភោគអាហារនៅខាងក្នុងតម្រូវឱ្យពាក់ទាំងរបាំងមុខធ្វើពីក្រណាត់និងខែលការពារមុខដើម្បីបង្កើនការ ការពារអតិបរិមាសម្រាប់ទាំងនិយោជិកនិងអតិថិជន។

លើសពីនេះទៀតនៅថ្ងៃទី ២៦ ខែមិថុនាហាងថែសម្ផស្សនិងថែខ្លួនជាច្រើននឹងត្រូវបានអនុញ្ញាតឱ្យបើក ឡើងវិញ។ ក្នុងបទបញ្ជាសុខភាពមួយថ្មីដែលនឹងចេញនាពេលខាងមុខអ្នកផ្តល់សេវាត្រូវតែពាក់ខែល

ការពារមុខនៅពេលផ្តល់សេវាកម្មថែសម្ផស្សឬថែខ្លួនដែលតម្រូវឱ្យអតិថិជនដោះរបាំងមុខចេញដើម្បីផ្តល់សេវាកម្មបាន។

អ្នកតំណាងបារភោជនីយដ្ឋាននិងហាងថែសម្ផស្សនិងថែខ្លួនអាចមកយកខែលការពារមុខនៅចំណតរថយន្តការិយាល័យកណ្តាលរបស់មន្ទីរពន្លត់អគ្គីភ័យនៃឡុងប៊ិចដែលមានទីតាំងនៅ 3205 Lakewood Blvd។ ខែលការពារមុខមានកំណត់ត្រឹម ២០ ខែលក្នុងមួយហាងហើយអ្នកដែលមកដល់មុននឹងត្រូវបម្រើមុនរហូតទាល់តែខែលអស់។ អ្នកតំណាងអាជីវកម្មនីមួយៗនឹងត្រូវផ្តល់ឈ្មោះនិងឈ្មោះអាជីវកម្មរបស់ពួកគាត់ពេលដែលមកយកខែល។

ខែលនឹងមានសម្រាប់ការមកយកនៅថ្ងៃនិងម៉ោងដូចខាងក្រោម៖

- ថ្ងៃពុធទី ២៤ ខែមិថុនាពីម៉ោង ២ រសៀលដល់ម៉ោង ៤ ល្ងាច
- ថ្ងៃសុក្រទី ២៦ ខែមិថុនាពីម៉ោង ២ រសៀលដល់ម៉ោង ៤ ល្ងាច
- ថ្ងៃពុធទី ១ ខែកក្កដាពីម៉ោង ២ រសៀលដល់ម៉ោង ៤ ល្ងាច

ទីក្រុងឡុងប៊ិចបានចាប់ផ្តើមចែកខែលការពារមុខដោយឥតគិតថ្លៃដល់អាជីវកម្មដែលមានមូលដ្ឋាននៅឡុងប៊ិចកាលពីខែឧសភាហើយរហូតមកដល់ពេលនេះបានផ្តល់ខែលចំនួន 6,300 ខែល។

ការសាកសួរពីអ្នកសារព័ត៌មានអាចបញ្ជូនទៅកាន់មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិចនៅលេខ 562.570.NEWS (6397) ឬតាមរយៈអ៊ីម៉ែលទៅកាន់ jic@longbeach.gov។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័សង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###